**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល**
**(ខេមបូឌា) ភីអិលស៊ី**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការពន្យារពេលក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលនៅជាធរមាន ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ជូននិយ័តករមូលបត្រកម្ពុជា ("**ន.ម.ក**") យ៉ាងយូរបំផុតត្រឹម ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។ ដោយហេតុថា មានការឈប់សម្រាកសម្រាប់ពិធីបុណ្យជាតិច្រើន នៅក្នុងខែកញ្ញា និងវិច្ឆិកា កន្លងទៅ ក្រុមហ៊ុនមានការយឺតយ៉ាវក្នុងការរៀបចំបិទបញ្ជីគណនេយ្យ និងចាប់ផ្តើមដំណើរការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២២ ដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន និងពុំអាចបង្ហាញជូនវិនិយោគិន និងសាធារណជន ទាន់ពេលវេលា។

ការផ្តល់ជូនរបាយការណ៍ក្រុមហ៊ុន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២២ នេះ នឹងត្រូវពន្យាពេលរហូតដល់ **ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២**។ ក្រុមហ៊ុននឹងបង្ហាញជូនរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ នេះ ជូនវិនិយោគិន និងសាធារណជន បន្ទាប់ពីដាក់ជូន ន.ម.ក ពិនិត្យ និងសម្រេច។

អាស្រ័យដូចមានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៦ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**

GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA

ទីស្នាក់ការៈ ភូមិត្រពាំងពោធិ៍សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:២៣ ៨៩០ ៣២៥(៨៥៥) /ទូរសារ :២៣ ៨៩០ ៣២៦(៨៥៥) / គេហទំព័រ : www.Grandtwins.com.kh/អ៊ីម៉ែល : vuthy.phuong@qmico.com